# គំរូនៃទំនាក់ទំនងដ៏មានអត្ថន័យនៅក្នុងប្រវត្តិសាស្ត្រ សាសនាចក្រ និងគោលលទ្ធិ និងសេចក្ដីសញ្ញា

## គំរូទី ១

បន្ទាប់ពីលោកបានទៅភ្នំគូម៉ូរ៉ានៅខែកញ្ញា ឆ្នាំ១៨២៣ យ៉ូសែប ស៊្មីធ បានចែកចាយព័ត៌មានលម្អិតអំពីបទពិសោធន៍របស់លោក និងការយាងមកជួបរបស់ទេវតាមរ៉ូណៃជាមួយគ្រួសាររបស់លោក ។ យ៉ូសែបបានបន្តចែកចាយបទពិសោធន៍ និងទស្សនៈរបស់លោកជាមួយនឹងអ្នកដែលជិតស្និទ្ធនឹងគាត់បំផុត ។ កាលរំឭកអំពីការមកជួបដ៏ពិសិដ្ឋទាំងនេះ ម្ដាយរបស់ព្យាការី លូស៊ី ម៉ាក ស៊្មីធ បានកត់ត្រាដូចខាងក្រោមនេះ ៖



> រៀងរាល់ល្ងាចយើងបានប្រមូលកូនៗរបស់យើងមកជួបជុំគ្នា ។ ខ្ញុំគិតថា យើងបានបង្ហាញនូវទិដ្ឋភាពដ៏ចម្លែកបំផុតនៃគ្រួសារណាមួយដែលធ្លាប់រស់នៅលើផែនដី ទាំងអស់គ្នាអង្គុយនៅក្នុងរង្វង់ មានឪពុក ម្ដាយ កូនប្រុស និងកូនស្រីដែលស្ដាប់ចង់ភ្លេចដកដង្ហើមចំពោះការបង្រៀនខាងសាសនារបស់ក្មេងប្រុសម្នាក់ ។ . . .
>
> . . . ការជួបជុំគ្នា និងសុភមង្គលដ៏ផ្អែមល្ហែមបំផុតបានសាយភាយពេញផ្ទះរបស់យើង ។ គ្មានការមិនចុះសម្រុង ឬរំខានដល់សន្តិភាពរបស់យើងឡើយ ហើយភាពស្ងប់ស្ងាត់បានមាននៅក្នុងចំណោមពួកយើងទាំងអស់គ្នា ។ ( លូស៊ី ម៉ាក ស៊្មីធ នៅក្នុង *Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ២០០៧ ] ទំព័រ ៤៨៦ )

- តើអ្វីដែលលេចធ្លោជាងគេចំពោះអ្នកអំពីគ្រួសារ ស៊្មីធ ចេញមកពីដំណើររឿងនេះ ?
- តើសេចក្ដីស្រឡាញ់ដែលយ៉ូសែបមាននៅក្នុងផ្ទះបានជួយលោកឲ្យបំពេញការហៅដ៏សំខាន់របស់លោកដោយរបៀបណា ?
- តើអ្នករៀនអ្វីខ្លះមកពីគំរូនេះអំពីរបៀបដែលព្រះអាចប្រទានពរដល់អ្នក ឬរបៀបដែលអ្នកអាចជួយអ្នកដទៃឲ្យទទួលបានពរតាមរយៈទំនាក់ទំនងដ៏មានអត្ថន័យនោះ ?

## គំរូទី ២

ខណៈដែលកំពុងរស់នៅក្នុងទីក្រុងណៅវូ រដ្ឋអិលលីណោយ យ៉ូសែប ស៊្មីធ បានជញ្ជឹងគិតអំពីអត្ថប្រយោជន៍នៃទំនាក់ទំនងដ៏មានអត្ថន័យទាំងឡាយ ៖



> ខ្ញុំនឹងចាត់ទុកវាជាពរជ័យដ៏អស្ចារ្យមួយ ប្រសិនបើខ្ញុំត្រូវរងទុក្ខនៅក្នុងពិភពលោកនេះដើម្បីឲ្យខ្ញុំមានសំណាងដែលខ្ញុំអាចស្វែងរកបងប្អូន និងមិត្តភក្តិនៅជុំវិញខ្ញុំ ។ ( *Teachings: Joseph Smith* ទំព័រ ៤៦៦ )

- តើគ្រួសារ និងមិត្តភក្តិអាចជួយយើងបានយ៉ាងដូចម្ដេចនៅពេលយើងកំពុងជួបឧបសគ្គដ៏លំបាក ?
- តើគ្រួសារ និងមិត្តភក្តិអាចប្រទានពរដល់ជីវិតរបស់យើងតាមវិធីណាទៀត ?

## គំរូទី ៣

សូមអាន គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៨:៧ ដោយស្វែងរកដំបូន្មានដែលព្រះអម្ចាស់បានប្រទានដល់ ឡៃម៉ាន ស៊ើម៉ាន នៃពួកចិតសិបនាក់ ។

- ហេតុអ្វីពេលខ្លះវាពិបាកក្នុងការធ្វើតាមដំបូន្មាននេះ ?
- តើនៅពេលណាអ្នកមានអារម្មណ៍ថាត្រូវបានពង្រឹង ឬលើកទឹកចិត្តដោយការប្រាស្រ័យទាក់ទងជាមួយមនុស្សម្នាក់ទៀត ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_577-1